6 37/4

1 Dec/2020

# ព្រះរាជាណាចក្រកម្ពុជា
# ជាតិ សាសនា ព្រះមហាក្សត្រ

**សាលាដំបូងខេត្តព្រះវិហារ**

សំណុំរឿងព្រហ្មទណ្ឌលេខ:៥៨
ចុះថ្ងៃទី១២ ខែមីនា ឆ្នាំ២០២០
សាលក្រមព្រហ្មទណ្ឌ
លេខ:១២៣ "ខ"
ចុះថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០២០

## តាងនាមប្រជារាស្ត្រខ្មែរ
## សាលាដំបូងខេត្តព្រះវិហារ

បានបើកសវនាការជាសាធារណៈ នៅថ្ងៃទី០១ ខែ ធ្នូ ឆ្នាំ២០២០ និងប្រកាសសាលក្រមជាសាធារណៈ នៅថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០២០ នៅសាលាដំបូងខេត្តព្រះវិហារ ដែលមានសមាសភាពដូចតទៅ៖

**<u>ប្រធានក្រុមប្រឹក្សាជំនុំជម្រះ</u>**

-លោក **សែត វិសិដ្ឋមុនី** ជាអនុប្រធានសាលាដំបូងខេត្តព្រះវិហារ

**<u>ចៅក្រមប្រឹក្សា</u>**

-ឯកឧត្តម [redacted] ជាប្រធានសាលាដំបូងខេត្តព្រះវិហារ

-លោកស្រី [redacted] ជាចៅក្រមសាលាដំបូងខេត្តព្រះវិហារ

**<u>តំណាងអយ្យការ</u>**

-លោកស្រី [redacted] ជាព្រះរាជអាជ្ញារង នៃអយ្យការអមសាលាដំបូងខេត្តព្រះវិហារ

**<u>ក្រឡាបញ្ជីសវនាការ</u>**

-លោក [redacted] ជាក្រឡាបញ្ជីសាលាដំបូងខេត្តព្រះវិហារ

-លោក [redacted]រិទ្ធ ជាមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ

-លោក [redacted] សាំង ជាមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ

ដើម្បីជំនុំជម្រះសំណុំរឿងលេខ:៥៨ ចុះថ្ងៃទី១២ ខែមីនា ឆ្នាំ២០២០ ដែលមានជនជាប់ចោទ៖

១./ឈ្មោះ [redacted] សារេត ភេទស្រី អាយុ៤៤ឆ្នាំ ជាតិខ្មែរ កើតនៅភូមិតាបស ឃុំស្ពៅ ស្រុកសង្គមថ្មី ខេត្តព្រះវិហារ និងមានទីលំនៅមុនពេលចាប់ខ្លួនស្ថិតនៅ [redacted] (ស)./



Scanned with CamScanner

ម្ដាយឈ្មោះ [redacted] (ស) ប្ដីឈ្មោះ [redacted] (រ) មានកូនចំនួន០១ នាក់ ជានីតិជន។ ឃុំខ្លួនទៅថ្ងៃទី១៣ ខែមីនា ឆ្នាំ២០២០។

២./ឈ្មោះ [redacted] លុច ភេទប្រុស កើតឆ្នាំ១៩៧៥ ជាតិខ្មែរ កើតនៅភូមិតាបស ឃុំស្ដៅ ស្រុកសង្គមថ្មី ខេត្តព្រះវិហារ និងមានទីលំនៅបច្ចុប្បន្នស្ថិតនៅ [redacted] ម្ដាយឈ្មោះ [redacted]) ប្រពន្ធឈ្មោះ [redacted] សារេត (រ) មានកូនចំនួន០៣ នាក់ ជានីតិជន។ *មានដីកាបង្គាប់អោយចាប់ខ្លួន។*

ត្រូវបានចោទប្រកាន់ពីបទ កាប់គាស់ រុករានដីព្រៃ ឆ្ការ ដុត និងឈូសឆាយដីព្រៃ ដើម្បីធ្វើជាកម្មសិទ្ធិ [redacted] ស្រុកសង្គមថ្មី ខេត្តព្រះវិហារ កាលពីថ្ងៃទី១២ ខែមីនា ឆ្នាំ២០២០ តាមមាត្រា៦២ កថាខណ្ឌ១ នៃច្បាប់ស្ដីពីតំបន់ការពារធម្មជាតិ។

វត្ថុចាប់យករួមមាន៖ គោយន្តកន្ត្រៃ គ្មានរ៉ឺម៉កចំនួន០១ គ្រឿង តាមកំណត់ហេតុទទួលវត្ថុតាងលេខ២៤/២០២០ របស់លេខាធិការដ្ឋានរដ្ឋបាលសាលាដំបូងខេត្តព្រះវិហារ ចុះថ្ងៃទី១២ ខែមីនា ឆ្នាំ២០២០។

## អង្គហេតុនៃរឿងមានដូចតទៅ៖

កាលពីថ្ងៃទី១២ ខែមីនា ឆ្នាំ២០២០ ឈ្មោះ [redacted] សារេត និងឈ្មោះ [redacted] លុច បានប្រព្រឹត្តបទល្មើសកាប់ទន្ទ្រានរានយកដីព្រៃ និងបរបាញ់សត្វព្រៃដោយខុសច្បាប់ក្នុងតំបន់ការពារ ហើយមន្ត្រីសមត្ថកិច្ចបានធ្វើការណែនាំ និងអប់រំជាច្រើនលើកច្រើនសារួចមកហើយតែជនខាងលើនេះនៅតែប្រព្រឹត្តដដែល។

បានឃើញ ដីកាសន្និដ្ឋានស្ថាពលេខ:១២៨៨ ដ.ស.ព ចុះថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០២០ របស់តំណាងអយ្យការអមសាលាដំបូងខេត្តព្រះវិហារ ប្ដឹងសុំអោយចៅក្រមស៊ើបសួរបញ្ជូនជនត្រូវចោទឈ្មោះ [redacted] សារេត, [redacted] លុច ទៅជំនុំជម្រះពីបទ កាប់គាស់ រុករានដីព្រៃ ឆ្ការ ដុត និងឈូសឆាយដីព្រៃ ដើម្បីធ្វើជាកម្មសិទ្ធិ។

-បានឃើញ ដីកាដំណោះស្រាយលេខ៣០១៤/២០២០ ចុះថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០២០ របស់ចៅក្រមស៊ើបសួរសាលាដំបូងខេត្តព្រះវិហារ ដែលបញ្ជូនជនត្រូវចោទឈ្មោះ [redacted] សារេត, [redacted] លុច ទៅជំនុំជម្រះពីបទ កាប់គាស់ រុករានដីព្រៃ ឆ្ការ ដុត និងឈូសឆាយដីព្រៃ ដើម្បីធ្វើជាកម្មសិទ្ធិ។

## នាពេលសវនាការ

-ជនជាប់ចោទឈ្មោះ [redacted] សារេត ឆ្លើយថា៖ សមត្ថកិច្ចបានចាប់ឃាត់រូបខ្លួន កាលពីថ្ងៃទី១២ ខែមីនា ឆ្នាំ២០២០ នៅចំណុចព្រៃរំដេងដែលខ្លួនបានកាប់ឆ្ការ។ ខ្លួន និងប្ដីបានកាប់ឆ្ការដីនេះតាំងពីឆ្នាំ២០១០ រហូតដល់បច្ចុប្បន្នបានដីទំហំ៦ ហិកតា ខ្លួនបានដឹងថាដីនេះជាដីព្រៃដែលហាមឃាត់ តែខ្លួន និងប្ដីកាប់ឆ្ការជាដីព្រៃដែលមានព្រៃដុះតូចៗ មិនមានដើមឈើធំដុះទេ។ ចំពោះដីនេះខ្លួនបានដាំស្វាយ ចេក ដំឡូង ចន្ទី ដើម្បីបានប្រាក់ចិញ្ចឹមគ្រួសារ។ អំឡុងពេលដែលខ្លួនកាន់កាប់នោះក៏មានមន្ត្រីចុះមកអប់រំណែនាំដែរ ប៉ុន្តែខ្លួនក៏បានកាប់រានបន្តទៀតដែរ។

-សាក្សីឈ្មោះ [redacted] ញឹម ជាមន្ត្រីបរិស្ថានឆ្លើយថា៖ កាលពីថ្ងៃទី១២ ខែមីនា ឆ្នាំ២០២០ មន្ត្រីកងរាជអាវុធហត្ថលើផ្ទៃប្រទេសសហការណ៍ជាមួយនឹងមន្ត្រីឧទ្យានុរក្ស បានចុះដល់ទីតាំងកើតហេតុដែលយើងបានកសាងសំណុំរឿងបញ្ជូនសំណុំរឿងមកតុលាការម្ដងរួចមកហើយ លើករណីកាប់ទន្ទ្រានរានយកដីព្រៃដោយខុសច្បាប់ បរបាញ់សត្វព្រៃគ្រប់ប្រភេទ ប្រើ



Scanned with CamScanner

ប្រាស់អាវុធខុសច្បាប់ ហើយជនសង្ស័យ នៅតែបន្តសកម្មភាពកាប់ព្រៃដដែល ដោយសំអាងថា មិនទាន់គ្រប់ផែនការរបស់ខ្លួន។ ជនសង្ស័យឈ្មោះ [redacted] លុច ដែលជាប្តីរបស់ឈ្មោះ [redacted] សាវេត ក៏មានវត្តមាននៅទីនោះដែរ ពេលឃើញសមត្ថកិច្ចយើងចូលដល់ទីតាំងកើតហេតុ ក៏បានរត់គេចខ្លួនបាត់តែម្តង។ ឯជនសង្ស័យឈ្មោះ [redacted] សាវេត មិនបានរត់ទេនៅតតាំងជាមួយមន្ត្រីនៅកន្លែងកើតហេតុ។

-តុលាការអោយក្រឡាបញ្ជីអានកំណត់ហេតុទទួលវត្ថុតាងលេខ២៤/២០២០ របស់លេខាធិការដ្ឋានរដ្ឋបាលសាលាដំបូងខេត្តព្រះវិហារ ចុះថ្ងៃទី១២ ខែមីនា ឆ្នាំ២០២០ រួមមាន៖ គោយន្តកន្ត្រៃ គ្មានរ៉ឺម៉កចំនួន០១ គ្រឿង។

-ការធ្វើសេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ ក្រោយពីបានសួរដេញដោលចប់សព្វគ្រប់រួចមកឃើញថា ជនជាប់ចោទបានសារភាពអស់ហើយ ហេតុនេះ តំណាងអយ្យការសូមរក្សាបទចោទប្រកាន់ដូចដែលមាននៅក្នុងដីកាសន្និដ្ឋានស្ថាពរដដែល។

-ការសន្និដ្ឋានរបស់មេធាវីក្រោយពីបានស្តាប់ការពិភាក្សាដេញដោលរួចមកឃើញថា កូនក្តីរបស់ខ្លួនឈ្មោះ [redacted] សាវេត បានសារភាពអស់ហើយ ហេតុនេះសូមអោយតុលាការមេត្តាបន្ធូរបន្ថយទោសកូនក្តីខ្លួនផង។ ចំពោះកូនក្តីរបស់ខ្លួនឈ្មោះ [redacted] លុច បើទោះបីមិនបានចូលរួមសវនាការក្តី ខ្លួនសូមអោយតុលាការមេត្តាបន្ធូបន្ថយទោសកូនក្តីខ្លួនផង។

-ឈ្មោះ [redacted] សាវេត ៖ សូមអោយតុលាការមេត្តាបន្ធូបន្ថយទោសខ្លួនផង។

-ក្រោយពីបានពិភាក្សាសួរដេញដោលនាពេលសវនាការ

-ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] សាវេត

-ក្រោយពីបានស្តាប់ចម្លើយរបស់សាក្សី

-ក្រោយពីបានពិនិត្យឯកសារ និងភស្តុតាងនានាក្នុងសំណុំរឿង

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ

-ក្រោយពីបានស្តាប់សំដីចុងក្រោយរបស់ជនជាប់ចោទ

## ក្រោយពីបានពិនិត្យ និងពិចារណាត្រឹមត្រូវតាមច្បាប់ហើយ
## សាលាដំបូងខេត្តព្រះវិហារ យល់ឃើញថា

-តាមចម្លើយសារភាពរបស់ជនជាប់ចោទឈ្មោះ [redacted] សាវេត, ចម្លើយរបស់សាក្សីឈ្មោះ [redacted] ញឹម និងការពិនិត្យភស្តុតាងក្នុងសំណុំរឿងឃើញថា ពិតជាមាននូវអំពើ កាប់គាស់ រុករានដីព្រៃ ឆ្ការ ដុត និងឈូសឆាយដីព្រៃ ដើម្បីធ្វើជាកម្មសិទ្ធិ ប្រព្រឹត្តនៅឃុំស្តៅ ស្រុកសង្គមថ្មី ខេត្តព្រះវិហារ កាលពីថ្ងៃទី១២ ខែមីនា ឆ្នាំ២០២០ ដែលបង្កឡើងដោយជនជាប់ចោទឈ្មោះ [redacted] សាវេត និងឈ្មោះ [redacted] លុច ប្រាកដមែន។

-មានពិរុទ្ធភាពលើជនជាប់ចោទឈ្មោះ [redacted] សាវេត និងឈ្មោះ [redacted] លុច បានប្រព្រឹត្តនូវអំពើ កាប់គាស់ រុករានដីព្រៃ ឆ្ការ ដុត និងឈូសឆាយដីព្រៃ ដើម្បីធ្វើជាកម្មសិទ្ធិ ប្រព្រឹត្តនៅ [redacted] ខេត្តព្រះវិហារ កាលពីថ្ងៃទី១២ ខែមីនា ឆ្នាំ២០២០ តាមមាត្រា៦២ កថាខណ្ឌ១ នៃច្បាប់ស្តីពីតំបន់ការពារធម្មជាតិ។

-គ្មានភស្តុតាងណាបញ្ជាក់ថាជនជាប់ចោទឈ្មោះ [redacted] សាវេត និងឈ្មោះ [redacted] លុច ជាជនវិកលចរិក ឬវិបល្លាសស្មារតីឡើយ ផ្ទុយទៅវិញ ជនជាប់ចោទជាបុគ្គលមានសមត្ថភាពគ្រប់គ្រាន់ក្នុងការទទួលខុសត្រូវព្រហ្មទណ្ឌ។



Scanned with CamScanner

-ការតម្កល់បទចោទប្រកាន់របស់តំណាងអយ្យការតាមដីការសន្និដ្ឋានស្ថាពររបស់ខ្លួននាពេលសវនាការ គប្បីតុលាការពិចារណា។

-ការប្រព្រឹត្តរបស់ជនជាប់ចោទដោយសារភាពអវិជ្ជា ក្រីក្រខ្វះការអប់រំ គប្បីតុលាការពិចារណាក្នុងការដាក់ទណ្ឌកម្មលើជននេះ។

-ការសន្និដ្ឋានរបស់មេធាវីសូមអោយតុលាការបន្ធូរបន្ថយទោសលើកូនក្តីរបស់ខ្លួន គប្បីតុលាការពិចារណាសម្រេច។

-ជនជាប់ចោទឈ្មោះ [redacted] សាវេត សុំអោយតុលាការមេត្តាបន្ធូរបន្ថយទោសខ្លួនផង គប្បីតុលាការពិចារណា។

-វត្ថុចាប់យករួមមាន៖ គោយន្តកន្ត្រៃ គ្មានរ៉ឺម៉កចំនួន០១ គ្រឿង តាមកំណត់ហេតុទទួលវត្ថុតាងលេខ២៤/២០២០ របស់លេខាធិការដ្ឋានរដ្ឋបាលសាលាដំបូងខេត្តព្រះវិហារ ចុះថ្ងៃទី១២ ខែមីនា ឆ្នាំ២០២០ គប្បីតុលាការពិចារណាសម្រេចរឹបអូសជាទ្រព្យសម្បត្តិរដ្ឋ។

## ហេតុដូច្នេះសាលាដំបូងខេត្តព្រះវិហារ
## វិនិច្ឆ័យសេចក្តី

១./ផ្តន្ទាទោសជនជាប់ចោទឈ្មោះ [redacted] សាវេត ភេទស្រី អាយុ៤៤ឆ្នាំ (សាវតាជាតិដូចមានខាងលើ)ដាក់ពន្ធនាគារកំណត់ ៥ (ប្រាំ) ឆ្នាំ ពីបទ កាប់គាស់ រុករានដីព្រៃ ឆ្ការ ដុត និងឈូសឆាយដីព្រៃ ដើម្បីធ្វើជាកម្មសិទ្ធិ ប្រព្រឹ[redacted] សង្គមថ្មី ខេត្តព្រះវិហារ កាលពីថ្ងៃទី១២ ខែមីនា ឆ្នាំ២០២០ តាមមាត្រា៦២ កថាខណ្ឌ១ នៃច្បាប់ស្តីពីតំបន់ការពារធម្មជាតិ

-ផ្តន្ទាទោសជនជាប់ចោទឈ្មោះ [redacted] លុច ភេទប្រុស កើតឆ្នាំ១៩៧៥ ជាតិខ្មែរ (សាវតាជាតិដូចមានខាងលើ) ដាក់ពន្ធនាគារកំណត់ ៦ (ប្រាំមួយ) ឆ្នាំ ពីបទ កាប់គាស់ រុករានដីព្រៃ ឆ្ការ ដុត និងឈូសឆាយដីព្រៃ ដើម្បីធ្វើជាកម្មសិទ្ធិ ប្រព្រឹត្តនៅ [redacted] ខេត្តព្រះវិហារ កាលពីថ្ងៃទី១២ ខែមីនា ឆ្នាំ២០២០ តាមមាត្រា៦២ កថាខណ្ឌ១ នៃច្បាប់ស្តីពីតំបន់ការពារធម្មជាតិ។

២./វត្ថុចាប់យករួមមាន៖ គោយន្តកន្ត្រៃ គ្មានរ៉ឺម៉កចំនួន០១ គ្រឿង តាមកំណត់ហេតុទទួលវត្ថុតាងលេខ២៤/២០២០ របស់លេខាធិការដ្ឋានរដ្ឋបាលសាលាដំបូងខេត្តព្រះវិហារ ចុះថ្ងៃទី១២ ខែមីនា ឆ្នាំ២០២០ ត្រូវរឹបអូសជាទ្រព្យសម្បត្តិរដ្ឋ។

សាលក្រមនេះជំនុំជម្រះនៅថ្ងៃទី០១ ខែ[illegible] ឆ្នាំ២០២០ និងប្រកាសជាសាធារណៈនៅថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០២០ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] សាវេត និងកំបាំងមុខជនជាប់ចោទឈ្មោះ [redacted] លុច បើភាគីមិនសុខចិត្តនឹងសេចក្តីសម្រេចនេះមានសិទ្ធិប្តឹងទាស់, ប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់។

**ក្រឡាបញ្ជីសវនាការ** **ចៅក្រមប្រឹក្សា** **ចៅក្រមប្រឹក្សា** **ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**

ហត្ថលេខា និងត្រា [redacted] ហត្ថលេខា និងត្រា [redacted]

បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម

ថ្ងៃសុក្រ ២កើត ខែមាឃ ឆ្នាំជូត ទោស័ក ព.ស២៥៦៤

ខេត្តព្រះវិហារ ថ្ងៃទី១៥ ខែមករា ឆ្នាំ២០២១

ក្រឡាបញ្ជី

បានឃើញ

ប្រធានក្រុមប្រឹក្សាជំនុំជម្រះ

[redacted]

[redacted]



Scanned with CamScanner